# រ៉ាម៉ុនហៅមន្ត

គេឈរនៅក្បែរកុម្ភៈ ខណៈពួកប្រុសអឺរ៉ុបជាច្រើន សម្លឹងមកយើង។ រ៉ាម៉ុនមិនប្រាកដថា តើកន្លែងនេះអាចមានសុវត្ថិភាពដូចនៅអាមេរិកដែរទេ គេទើបតែបង្កើតអនុស្សាវរយប់ដំបូងនៅភ្នំពេញ។

ហើយ...ហេតុអ្វីបានជាប្រុសៗអឺរ៉ុបមើលមកយើង? គេសួរតិចៗ រក្សាស្មារម្ដើៗយ៉ាងជឿជាក់។

«ឯងជាគោលដៅរបស់ពួកហ្នឹង!»

«ស្អី?» គេតបទៅកាន់កុម្ភៈ មិត្តចាស់ទើបតែចួបគ្នាឡើងវិញ។

«គេដឹងថាឯងជាហ្គេយ៍! ហើយជាហ្គេយ៍ស្អាតជាងដែលធ្លាប់ឃើញមាននៅស្រុកខ្មែរ!»

រ៉ាម៉ុនក្ដាប់មាត់។ ទោះគ្រប់យ៉ាងបានធ្វើឱ្យបេះដូងគេកម្រើកក្ដៅៗនិងស្រស់ស្អាត តែប្រុសៗទាំងនេះ គ្មានអ្នកណាគួរឱ្យគេចាប់ចិត្តទេ។

នៅអាមេរិកគេមិនដែលមានភាពក្លាហានក្នុងការនិយាយជាមួយប្រុសស្អាតៗមាឌធំៗ ឬសូម្បីតែចេញទៅក្លឹបម្នាក់ឯង ទាល់តែមានកម្មវិធីឬមិត្តភក្តិ ម៉្លោះហើយ បេះដូងនេះ បានត្រឹមគេងកំព្រាជារឿយៗហាក់បីដូចជា នារីវ័យក្រមុំដ៏រមទម្យម្នាក់។

ស្រាដ៏ក្រអូបជាច្រើនកែវ បានត្រូវបង្ហើយ។ ភ្នែកគេក្រហម តែប្រាណគេនៅរវាសយ៉ាងមានមោទនភាពក្បែរកុម្ភៈ ដែលមានស្រីៗហួចហៅឡើងរាំជានិច្ច។ កុម្ភៈមានមាឌស្ដើងនិងខ្ពស់តែមិនណែនណាន់សាច់ដូចជារ៉ាម៉ុនទេ។

«មន្ត!»

គេហៅរ៉ាម៉ុនដោយប្រើឈ្មោះខ្មែរ ដែលម្ចាស់ខ្លួនសឹងភ្លេចទៅហើយ។ កុម្ភៈបក់ដៃហៅគេ។ ហ៊ឹម! ចង់ឡើងរាំដែរ តែពួកបារាំងនៅពេញនោះ ពួកនោះងាកមកវាយភ្នែក ខ្លះលើកកដៃបង្ហាញសញ្ញា Pink Triangle តែមន្តរបស់យើង ងាកបែរខ្នងមិនដើរទៅ ថែមធ្វើជាមិនចាប់អារម្មណ៍។

វប្បធម៌មួយដែលឃើញគ្នាភ្លាម ដោះអាវភ្លែត វាហួសពីការគិតនិងវិធីសាស្ត្រអាចទទួលយកបានសម្រាប់កូនខ្មែរសញ្ជាតិអាមេរិកម្នាក់នេះស្រាប់គេ។

«Hi ខ្ញុំឈ្មោះ វេហា»

សំឡេងពីរោះ មាឌខ្ពស់ ក្លិនប្រហើរ ងាកមកខ្ញាច់ ទ្រូងភាំង បេះដូងដួរចង្វាក់។ ប្រុសម្នាក់ ដៃសរសៃសសូង មួរអាវពណ៌ទឹកប៊ិចចេញកំភួន មានចិញ្ចៀនទម្រង់សិង្ហមួយចំកណ្ដាលដៃស្ដាំអមដោយចិញ្ចៀនពណ៌ប្រាក់ពីរទៀតសឹងគ្មានម្រាមណាមួយទំនេរទេ។

មន្តងាកស្ពឹកៗសម្លឹងជុំវិញ....គ្មានមនុស្សផ្សេង។ អ្នកលាយស្រាកំពុងនិយាយទូរសព្ទ អ៊ីចឹង គេនេះនិយាយជាមួយអ្នកណា?

ឱ! វេហា! ប្រែថាមេឃ! សមម្ល៉េះនឹងវិសាលភាពនៃអំណាចទាក់ទាញរបស់គេ។ ដៃគេបោះមកហើយ មានស្នាមសាក់ Lambda តូចសៃនតូច។

ភាំងតែធ្វើពុតជាងើយមុខក្លាហាន ធ្វើជាប្រុសពិតៗនិងមិនលង់គេ ហើយក៏បោះដៃទៅ។

«មន្ត! វ៉ាម៉ុន....បង!»

«ហៅមន្តពីរោះជាង!»

មន្តរបស់យើងញញឹម បន្លប់ទុក្ខនៃការចង់បាន។ វាប្រៀបដូចជាសេចក្ដីប្រាថ្នាមួយ កើតឡើងភ្លាមៗ ហើយធំ វាប្រៀបបីដូចជាយើងដើរកាត់ហាង Rolex ហើយដឹងជាស្រេច វាស្អាតណាស់ តែយើងនឹងមិនមានលុយទិញទេ។

គេនេះមកដល់ពីក្រោយខ្នង និយាយឈ្មោះ គ្មាននាមត្រកូល គ្មានការពន្យល់អំពីមូលហេតុដែលគេត្រូវមករករាក់ទាក់ ឬគាត់ជានរណា ហើយគ្រាន់តែប្រាប់ឈ្មោះប៉ុណ្ណោះក៏មកចាត់ចែង ថាមួយណាគួរប្រើ មួយណាគួរអត់?

ស្អែកនេះ ប្រូហ្វាល់ដូរមកឈ្មោះខ្មែរវិញហើយខ្ញុំ។ លបគិតម្នាក់ឯងស្ងាត់ៗ។

«ខ្ញុំឡង់ឌី» អ្នកចាក់ស្រាអុកកែវ Vodka Cranberry មកលើតុដោយនិយាយទៅរក«គេហ៍» តែឆ្លៀតមិចភ្នែកដាក់ខ្ញុំ។

មន្តអួលដើមកដោយមិនដឹងរៀបឫកបែបម៉េច ព្រោះអាការៈបងចាក់ស្រា ក៏ជាសេរីពួកយើងដែរ។ គាត់ត្រូវបានប្រុសស្អាតដាក់ដៃស្ដាំលើស្មា ហើយញាក់ចិញ្ចើមប្រាប់៖

«Cosmo baby bear»

មន្តរបស់យើងអត់មានពុកចង្កាទេ តែដូចចេះច្រណែនចង់ឱ្យគេហៅខ្លួនដូច្នឹងដែរ។

សំណួររបស់បុរសមុខរឹងចិត្តទន់ម្នាក់នេះ ផុសចេញមកយ៉ាងលឿន«និស្ស័យឬកម្ម?»។ ហើយសូម្បីតែពេលគេលើកកែវមកជឹបធ្វើពើជាប្រុសស្អាតតូចច្រម៉ក់មិនដឹងខ្យល់ មិនខ្វល់អ្វី ក៏ស្ដាប់ទៅបេះដូងនេះដូចជារលាមខ្លាំង និងចេញចរិតវាពិតមកឱ្យខាងតែបានគ្រាន់តែធុំក្លិន Brother វេហាក្បែរៗ។

តាមរយៈកន្ទុយភ្នែក បុរសម្នាក់នេះ ដ៏ធំសម្បើមនិងដ៏សង្ហា ដ៏គ្រោះថ្នាក់នៅតែសម្លឹងមកមន្តដូចជាគាត់នឹងសង្គ្រប់វាយបង្ក្រាបមន្ត ហើយ....មន្តមិនប្រាកដថា នឹងបញ្ឈប់ឬរារាំងគេទេ ប្រសិនមែន។

ដោយក្រឡេកមើលកែវស្រារបស់មន្ត វេហាញាកស្មាតិចៗ ហើយសួរៈ

«មកប៉ុន្មាននាក់?»

មន្តវេភ្នែកសម្លឹងភាពស្រទន់នៃដួងនេត្រាសងខាងម្ចាស់សំណួរ។ ចង់ប្រាប់គេថា យូរណាស់ហើយ តាំងពីបែកជាមួយប្រុសចិនម្នាក់នៅអាមេរិក មិនដែលមានសង្សារថ្មីទេ។ រមទម្យណាស់រាងកាយនេះ តែចិត្តវិញ មិនដឹងទេ អាចជាពេស្យាម្ដងៗ។

ចុះគេមានសួររឿងហ្នឹងឯណា ម៉េចក៏ចិត្តនេះគិតវែងឆ្ងាយបែកអូរហូរស្ទឹងទៅហើយ? អ៊ីចឹងបានលោកសម្ដែងថា ចិត្តមនុស្សរាយមាយណាស់ ហើយក៏កញ្ច្រោលបោកបក់សម្បើមដៃ ប្រសិនយើងមិនចេះទប់វា។

«បាទ២នាក់!»

គេមើលទៅខកចិត្តពេលឮចម្លើយ។ ប្រហែលគិតថា មន្តនេះមាននាំ Dude មកដែរ? មន្តដូចជាយល់ចិត្ត គេក៏ដៀងភ្នែកទៅរកកុម្ភៈ។ វេហាងាកស្មាបន្តិច រួចងាកទៅមើលដែរ។

មន្តចង្អុលៈ

«កុម្ភៈ! មិត្តខ្ញុំនៅស្រុកខ្មែរ...បែកគ្នាជាង៨ឆ្នាំហើយ!»

«មន្តទៅអាមេរិករៀន?»

អ្នកណាប្រាប់គេ? អូនឹកឃើញហើយ Symbol លើអាវយឺតនេះ ក្បែរទ្រូងឆ្វេង។ មន្តវេភ្នែកមើលរូបប៉ាក់តូចមួយឈ្មោះសង្កាត់ដែលគេរស់នៅ។ វាជាអាវដែលក្រុមគេបោះពុម្ពអបអរបុណ្យឯករាជ្យជាតិ។ មន្តតែងតែយល់ថា ខ្លួនឯងស្អាតនិងស្រួលខ្លួនជាមួយអាវយឺតមួយនេះ។

ទោះយ៉ាងណាគេនេះ គឺវេហា....គេជាមនុស្សឆ្លាតបំផុតហើយនៅភ្នំពេញ។

គ្រប់យ៉ាងល្អៗ ដូចជាបានប្រមូលមកលើខ្លួនគេតែម្នាក់។ ទាំងទាក់ទាញ រួសរាយ និងស្រស់ស្អាតគួរឱ្យចង់តែដណ្តើម។

គឺប!

មិនមែនអ្នកក្រឡុកស្រាដាក់ Cosmo មកឱ្យទេវបុត្រទេ តែវត្តមានអ្នកសក់វែងម្នាក់។ នាងស្លៀកសំពត់ខើចផ្លេកៗពណ៌ទឹកប្រាក់ មានអាវកំបិតពណ៌សត្រឹមទ្រូង និងបង្ហាញពោះទទេ។

នាងមានសុជន់មួយគូដែលទិញមក ព្រោះក៏ជាប្រុសដូចពួកយើងដែរ។

«ខ្ញុំយកកែវហ្នឹង!»

នាងចង្អុលមកកែវដែលអ្នកចាក់ស្រាកំពុងបែរខ្លួនកាន់មក។ ភ្នែកឡង់ឌីមើលមកវេហា មន្តក៏ងាកមុខចេញព្រោះធុញការចែចង់លឿនៗរបស់គូប្រជែង។

ស្រាប់តែអ្នកណាម្នាក់បានលូកមកច្របាច់កែងដៃរបស់គេថ្មមៗ។ មន្តគាំង ខណៈអណ្តាតក៏រឹងដូចស្លាប់។ វេហាបានឱ្យស្រានោះទៅមនុស្សសក់វែង តែគេឱ្យការប៉ះដ៏អស្ចារ្យមួយមកលើស្បែកមន្ត។

ខានបែបនេះយូរណាស់មកហើយ....ចង់និយាយថា អារម្មណ៍បែបនេះ។ មន្តដកដង្ហើមធំ ដកដៃខិតបន្តិចហើយនិយាយខ្សឹបៗ៖

«ខ្ញុំមិនរំខានកុម្ភៈទេ!»

ប្រុសខ្មែរអាមេរិកធ្វើឱ្យបងវេហាក្រឡេកទៅមើលកុម្ភៈដែលឱបរឹតជាមួយប្រុសបារាំងភ្នែកខៀវដូចពួកអ៊ីតាលី។ មន្តលើកអកស្រាវីបប្រុងចាកចេញចោលចរិតអត់របបរបស់បេះដូង តែវេហាដឹងថាមន្តមិនប្រចណ្ឌជាមួយកុម្ភៈទេ.....មន្តខឹងមនុស្សសក់វែង។

«ទៅដែរ!» វេហាញញឹម ធ្វើឱ្យមន្តភាំង។ មាត់នេះសឹងតែសួរថា «ជាប់ជើង?» តែមិនបានសួរផង គេត្រូវបានទាញឱ្យបែរខ្នង ហើយបន្ទាប់មកមន្តដើរចេញតាមវេហាដូចត្រូវបានចុចតេឡេបញ្ជារាងកាយ។

វេហាខ្ពស់ជាងមន្តមិនដល់បីធ្នាប់ម្រាមទេ តែអាចបង្វែរមន្តរបស់យើងបានយ៉ាងងាយស្រួលកាត់តាមចរន្តពពាក់ពពូននៃហ្វូងមនុស្សប្រញាយរីករាយ។ មនុស្សជាច្រើនគេចមកព្រោះកត់សម្គាល់អំពីសម្រស់គេ រឹតតែជំរុញមន្តឱ្យចង់«ចាប់»គេ ប៉ុន្តែបន្ទាប់មក....សំឡេងមួយលាន់ពីក្រោយខ្នងពួកគេ....

«ខ្ទើយខ្ចាត់ព្រាត់»

ដោយចងចិញ្ចើម មន្តឈប់ដើង ហើយងាកក្រោយសន្សឹមៗ។ មនុស្សសក់វែងលេងក្បាលពោះម្នាក់នោះ បាញ់គ្រាប់កាំភ្លើងច្រណែនចេញពីពន្លឺភ្នែករបស់នាងទាំងសងខាង សម្លឹងមកមន្តដែលត្រូវបានវេហាបណ្ដើរចេញ។

ម្រាមនាងមានកែវ COSMO ហើយនៅមិនស្រន់កំហឹង មកជេរ គប់ជាពាក្យសម្ដីបានទៀត។

«ស្អីគេ?» មន្តហាមាត់សួរវិញភ្លាមព្រោះទីនេះរាងថ្លង់។ ឡង់ឪគោះតុតិចៗ សុំឱ្យពួកគេស្ងាត់។ ឯវេហាដែលមុននេះកៀកស្មា ក៏លើកម្រាមមកចាប់ដៃមន្ត។

«ចាំសិន! ខ្ញុំចង់សួរអាសក់វែង!»

មន្តពោលឆ្ងាសៗព្រោះចង់ដឹងថា ហេតុអ្វីបានជាមនុស្សនេះមកជេរគេឯងបាន តែវេហាមិនឈប់ទេ រហូតដល់«ខ្ទើយខ្ចាត់ព្រាត់»ត្រូវប្រុសភ្នំពេញបណ្ដើរចាកចេញទៅបានសម្រេច។ មកដល់ខាងក្រៅ រាងមានខ្យល់ដក ព្រោះភ្លេងក៏លាន់ខ្សោយ សំឡេងមនុស្សស្រវឹងអត់មាន ចំណែកខ្យល់រាត្រីពិតជាពិសេសជាងខ្យល់ម៉ាស៊ីនត្រជាក់លាយក្លិនជាតិស្រវឹងនៅខាងក្នុង។

«អស់អីហើយ! លែងពុលហើយ!» គេនិយាយតិចៗតែមានរបៀបញ៉ែពេញមួយទំហឹងក្នុងខ្យល់ដង្ហើមរបស់គេ។

មន្តដកដៃលែងឱ្យប៉ះគ្នា និងរុញខ្លួនគេថ្នមៗ។ ជាតិ Vodka Cranberry នៅចំហាយឈ្ងុយក្បែរមាត់មន្ត តែគេមិនហ៊ានសូម្បីតែលិឍមាត់ ខ្លាចក្រែងថា ជនម្នាក់សែនឆ្លាតក្បែរប្រាណម្នាក់នេះ ម៉ែឃើញដល់រឿងផ្សេង។

«ងងុយគេង?»

គេសួរមកទៀត ធ្វើឱ្យពាក្យថា«លាហើយបង»នៅគាំងកណ្ដាលអាថ៌កំបាំងនៃបំពង់ក។ ដើងរបស់មន្តធ្ងន់ឡើងៗពេលខំគេចចេញពីការទាមទារនៃបេះដូងចេញមក ឆ្ងាយពីហ្វូងមនុស្សដែលកំពុងរង់ចាំចូលក្លឹប ហើយខិតទៅជិតចំណតឡានងងឹតនៅផ្នែកម្ខាង។

យប់មួយដ៏ឯកានេះ ខ្យល់រាត្រីលួងលោមបែបនេះ បានប្រុសល្អម្នាក់នេះមកនៅក្បែរគ្នា ប្រហែលជាអាចភ្លេចលោកនេះទាំងមូលបាន។ តែមន្តមិនគិតថា វារហ័សបែបនេះទេ។ គេលូកដៃរាវរកទូរសព្ទមកចុចហៅរ៉ឺម៉ក។

«ធ្វើអ្វី?» វេហាសួរហើយមកឈរក្បែរថែមឈ្ងោកមើល។

«ខ្ញុំហៅអីជិះទៅផ្ទះ!»

«ឡានខ្ញុំនុះ!»

គេចុចតេឡេទាំងភ្នែកស្រឹមៗពេញដោយទំនុកចិត្តសម្លឹងមកមន្ត។ មន្តងាកទៅ វាជាឡានអាមេរិកកាំងជំនុំតែមិនថោកទេ។

«ខ្ញុំអត់រំខានបងទេ!» មន្តនិយាយហើយញញឹមបែបសុភាព។

«តែបងចង់រំខានមន្ត!»

ប្រុសក្មេងសម្លឹងបងវេហាដែលញញឹមហាមាត់បង្ហាញអណ្ដាត។ ភ្នែកគេពណ៌នាថា គេនឹងថ្នាក់ថ្នមមន្តដូចជាពិទូសូរកានបើមានឱកាស។ សភាពនេះបានធ្វើឱ្យមន្តស្ថិត ក្នុងភាពទាល់ច្រកព្យាយាមញញឹម ពន្យារពេលរកពាក្យមកបដិសេធ។ កុម្ភៈវក់ប្រុសបារាំងហើយ កុំសង្ឃឹមថាចេញមកជួយចំពេលសម្រាលស្ថានការណ៍។ ពេលនេះជាពេលដែលមន្តខ្លួនឯងត្រូវដោះស្រាយ។

មនុស្សនៅភ្នំពេញ....មន្តមិនគួរឆាប់ជឿគេពេកទេ។ នេះជាអ្វីដែលកំលោះខ្មែរ-អាមេរិកាំងគិត។

ប៉ុន្តែ...វាជាការលំបាកខ្លាំងណាស់ក្នុងការធ្វើពើអត់ចាប់អារម្មណ៍ជាមួយប្រុសមាឌធំដូចគេ គួរឱ្យទាក់ទាញដូចគេ ហើយនិងកំហឹង«sex» ខឹងៗដែលគេបញ្ចេញមកតាមភ្នែក។

បបូរមាត់របស់គេ នៅក្នុងបន្ទាត់ស្មើងមួយមានអំណាចគួរឱ្យខ្លាច ព្រឺ និងចង់«លោ» ប៉ុន្តែពាក្យមួយទៀតក្នុងខួរក្បាលនៅតែ«មិនអាច»....។

«បងទៅមុនទៅ ខ្ញុំ....អត់ទេ! ចង់មានន័យថា ខ្ញុំអាចទៅផ្ទះដោយខ្លួនឯងបាន»

គេមិនឆ្លើយបែរមកក្រៀកក្រសោបស្មាមន្តហើយអូសទៅ។ មន្តដឹងថា មិនទៅទេ.....ម៉េចក៏ដោយតែជើងដែលហាត់នឿយនិងរាងកាយឯកោរបស់គេ ទីបំផុតបានបណ្ដោយឱ្យគេដើរតាមការក្រៀករបស់វេហា។

«ខ្ញុំ....ធ្វើម៉េចដឹងថា....បងឯងជាអ្នកណា?!»

«មិនរំលោភហើយសម្លាប់ទេ!» គេតបមកទាំងរុញមន្តចូលក្នុងទ្វារម្ខាង។ មន្តស្នេហ៍វេហារឹតតែមានអានុភាព សម្រាប់មន្តយើងកាន់តែពិបាកដើម្បីដោះលែងខ្លួនឯងពីបំណងប្រាថ្នាភ្លើតភ្លើនរោលរាលរបស់បេះដូងស្រីកាយជាប្រុស។

គេឈានចូលមកដល់ហើយអង្គុយក្បែរ។ មុនអីទាំងអស់គេ បញ្ឆេះនិងរុឺយែរយ៉ាងមាំទាំ។ ពេលងាកមកបប្ញូរមាត់របស់វេហាបើកចំហដោយញញឹមដុតរោលតែមិននិយាយអ្វីទាំងអស់។

រថយន្តចេញទៅហើយ។ មើលទៅគេនេះមិនមានបំណងជូនមន្តទៅផ្ទះទេព្រោះអត់ពោលសួរអាសយដ្ឋានមួយម៉ាត់សោះ។

គេបញ្ឆោទឡានកាត់តាមវិថីភ្លឺចិញ្ចាចនៃទីក្រុងតូច។

«យប់ដំបូងនៅភ្នំពេញ?»

គេសួរស្រាលៗកាត់សន្ទឹកម៉ោងនៃការប្រណាំងឡានម្នាក់ឯងរបស់ពួកស្រវឹងកណ្ដាលយប់។ មន្តមិងមាំង៖

«បាទ? ថាម៉េច?»

«យប់មិញគេងនៅឯណា?»

«ទៅតាមនោះទៅបង!»

គេសើចតិចៗតែមិនបត់តាមចង្អុលដៃក្មេងប្រុសទេ។

«បង! ទៅតាមនោះ!»

«ចុះបើបងមិនទៅ!»

«ខ្ញុំមិនយល់បងឯងទេ!»

«បងចង់ប្រដៅមន្តបន្តិច.....ឱ្យមានអារម្មណ៍ថា ធំគ្រប់គ្រាន់ ដើម្បីទទួលធ្វើតាមបេះដូងខ្លួនឯង!»

ពេលដែលមន្តព្រិចភ្នែកដូចជាមិនឮ ឬមិនយល់ពាក្យពេចន៍មាន password របស់គេ វេហាយល់ហើយ មន្តអាចគិតថា វេហានិយាយទាំងកំពុងស្រវឹង ឬមន្តខ្លួនឯងកំពុងស្រវឹង។

«គ្មានអ្នកណាឡើងឡាននេះហើយ បញ្ឆោទបងកាច់ចង្កូតតាមចិត្តទេ!»

គេនិយាយព្រោះចិត្តប្ដេជ្ញាថាត្រូវតែដោះអាវប្រុសក្មេងខ្មែរ-អាមេរិកម្នាក់នេះ និងនៅក្នុងយប់នេះឱ្យខាងតែបាន។ ការមិនចង់ស្ដាប់បង្គាប់ ជាចរិតចចេសដែលមន្តមាន នៅក្នុងកែវភ្នែកពេលសម្លឹងមកវេហាពេលនេះ។ នៅខណៈភ្នែកទាក់គ្នា មន្តក្ដាប់មាត់មាយាហើយដៀងមកមើលស្នាម **Lambda** លើដៃគេ។

«ខ្ញុំសម្រេចចិត្តខុស?»

គេរអ៊ូរទាំដោយរករភ្នែកសម្លឹងសងខាងផ្លូវ។

«អត់ទេ!» វេហាប្រកែកជាមួយសម្ដីទោមនស្សរបស់មន្ត។ គេបង្កើនល្បឿន ទាញរថយន្តរលូននៅលើទ្រូងផ្លូវហើយការបោលឆ្ងាយៗទៅកំពុងធ្វើឱ្យត្របកភ្នែកមន្តធ្ងន់ណាស់ សឹងមិនអាចបើករួចទៀត។

**វេហាហៅព្រាន Lambda**

ឃើញគេក្នុងបារភ្លាម វេហាគិតថា បុរសក្មេងមាន់ថ្មីម្នាក់នេះសាកសមនឹងឱ្យឱបក្រសោបគ្រប់គ្រង។ គេអាចសម្លាប់ Gays ផ្សេងៗបាន ជាមួយឫកពាសុភាពៗទន់ៗ និងស្រស់ល្អគន់មិនងាយបានឃើញ។

គេគេងហើយ។

វេហាសម្លឹងទាំងញញឹម។

គេមិនបានស្រែកឬប្រកែក ឬខឹង ហើយគេក៏មិនបានព្រម តែតាមរូបរាងដែលគេមាននៅពេលនេះ ក្លិនខ្លួនគេ រៀមច្បងប្រាកដថា គេមិនចង់សម្លាប់មន្តនៅយប់នេះ តែក៏មិនពន្លែងឱ្យមន្តបានទៅអ្នកដទៃដែរ។

ក្រៅអំពីការរួមភេទ វេហាជាមនុស្សគ្រប់គ្រងដៃគូ។

គេចង់បាន«ប្រពន្ធ»ម្នាក់ ជាមនុស្សប្រុស តែព្រមមកជា«របស់គេ»។ សម្រាប់វេហា មន្តម្នាក់នេះទន់ភ្លន់ និងជា Gay ដែលគួរឱ្យចង់ថ្នមបំផុត។